


## អំពីគម្រោងឡាសិត ៣ (LASED III)

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី ៣ (ឬហៅកាត់ថា គម្រោងឡាសិត ៣) គឺជាគម្រោងបែងចែកដីជូនដល់ប្រជាពលរដ្ឋក្រីក្រគ្មានដី និងមានដីតិចតួចសម្រាប់តាំងទីលំនៅ និងធ្វើកសិកម្ម ក្រោមកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់គ្រួសារក្រីក្រគ្មានដី និងមានដីតិចតួចឱ្យមានភាពប្រសើរឡើង។ គម្រោងឡាសិត ៣ មានគោលបំណងផ្តល់ជូនគ្រួសារកសិករ និងសហគមន៍ដែលតាំងទីលំនៅនៅក្នុងតំបន់គម្រោងនូវលទ្ធភាពទទួលបានសិទ្ធិកាន់កាប់ដីលំនៅឋាន និងដីកសិកម្មប្រកបដោយសុវត្ថិភាព សេវាសង្គមកិច្ច និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗគាំទ្រដល់ការកសាងជីវភាពថ្មី តាមរយៈកម្មវិធីដីសម្បទានសង្គមកិច្ច។ គម្រោងនេះ ក៏គាំទ្រផងដែរលើដំណើរការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ដើម្បីធានាដល់សុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីរបស់ជនជាតិដើមភាគតិច និងរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ។

THE WORLD BANK
IBRD • IDA

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌ សែនសុខ រាជធានីភ្នំពេញ
វេបសាយត៍៖ www. mlmupc.gov.kh
ហ្វេសប៊ុក៖ https://www.facebook.com/mlmupc.pressteam

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី ៣
Land Allocation for Social and Economic Development Project III (LASED III)

# យន្តការដោះស្រាយបណ្តឹងតវ៉ា
## សម្រាប់ភាគីដែលរងផលប៉ះពាល់ដោយសារ គម្រោងឡាសិត ៣




## យន្តការដោះស្រាយបណ្តឹងតវ៉ា ជាអ្វី?

យន្តការដោះស្រាយ **បណ្តឹងតវ៉ា** គឺជាប្រព័ន្ធមួយ ដែលគម្រោងរៀបចំឡើងដើម្បីទទួលការសម្តែងចេញអំពីកង្វល់ ផលប៉ះពាល់ និងធ្វើការឆ្លើយបំភ្លឺ ឬដោះស្រាយឆ្លើយតបទៅនឹងបញ្ហា ដែលកើតចេញពីការអនុវត្តសកម្មភាពរបស់គម្រោង ហើយបណ្តឹងតវ៉ា ត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ យន្តការដោះស្រាយបណ្តឹងនេះ បង្កើតឡើងសម្រាប់បុគ្គលគ្រប់រូប ដែលគិតថា ពួកគេបានរងផលប៉ះពាល់អវិជ្ជមានដោយសកម្មភាពរបស់គម្រោងឡាសិត ៣ (LASED III) រួមមាន÷ ១. ដំណើរការផ្តល់ដីសម្បទានសង្គមកិច្ច ២. ការចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច និង ៣. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងកសិកម្មនៅលើទីតាំងដីសម្បទានសង្គមកិច្ច និងដីរបស់សហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជីរួច។ បុគ្គលគ្រប់រូប មានសិទ្ធិប្រើប្រាស់យន្តការនេះ ដោយគ្មានការរឹតត្បិត ដើម្បីឱ្យពួកគេទទួលបានភាពយុត្តិធម៌ និងតម្លាភាពតាមរយៈដំណោះស្រាយសមស្របមួយ។ យន្តការនេះ នឹងត្រូវអនុវត្តតែក្នុងក្របខ័ណ្ឌគម្រោងឡាសិត ៣ ប៉ុណ្ណោះ។

# យន្តការដោះស្រាយបណ្តឹងតវ៉ា សម្រាប់ភាគីដែលរងផលប៉ះពាល់ដោយសារ គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី ៣ (LASED III)

## តើនរណាខ្លះមានសិទ្ធិដាក់បណ្តឹងតវ៉ា?

- ប្រជាពលរដ្ឋទាំងអស់ដែលគិតថា នឹងទទួលរង ឬបានទទួលរងផលប៉ះពាល់ជាអវិជ្ជមានដោយសារការអនុវត្តសកម្មភាពគម្រោងឡាសិត៣ (LASED III) នៅក្នុង ឬក្បែរសហគមន៍មូលដ្ឋានរបស់ពួកគាត់។
- បុគ្គលិក កម្មករគ្រប់រូប ឬអ្នកតំណាង ដែលគិតថាទទួលរងផលប៉ះពាល់ ដូចជា ការកេងប្រវ័ញ្ច ការរំលោភបំពានលើសិទ្ធិ សុវត្ថិភាព និងសុខភាព ពីអ្នកម៉ៅការ/ អ្នកផ្តល់សេវា/ អ្នកផ្គត់ផ្គង់ នៅក្នុងគម្រោងឡាសិត៣ (LASED III)។

## ផលប៉ះពាល់បណ្តាលមកពីការអនុវត្តសកម្មភាពគម្រោងមានអ្វីខ្លះ?

- ផលប៉ះពាល់លើសេដ្ឋកិច្ចគ្រួសារ ឬជីវភាពរស់នៅ
- ផលប៉ះពាល់លើផលដំណាំ ឬការចិញ្ចឹមសត្វ
- ការរឹតបន្តឹងសិទ្ធិចូលប្រើប្រាស់ដីដែលពួកគាត់បាននិងកំពុងប្រើប្រាស់
- ផលប៉ះពាល់ទៅលើសុវត្ថិភាព និងសុខភាពសហគមន៍ (ការបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍ ការបំពុលទឹកប្រើប្រាស់ បង្កសម្លេងរំខាន និងការហុយធូលីដី ។ល។)។
- ការកេងប្រវ័ញ្ចផ្លូវភេទ ឬការរំលោភបំពានផ្លូវភេទ
- អំពើហិង្សាលើស្ត្រី និងកុមារី
- ភាពគ្មានសុវត្ថិភាពលើការបំពេញការងាររបស់បុគ្គលិក កម្មករ ដែលក្រុមហ៊ុនម៉ៅការបានចុះកិច្ចសន្យាជាមួយគម្រោងឡាសិត៣ (LASED III)។
- បញ្ហាពាក់ព័ន្ធផ្សេងទៀត

## កន្លែងទទួលពាក្យបណ្តឹងតវ៉ា

ប្រសិនបើ លោកអ្នកទទួលរងផលប៉ះពាល់ណាមួយ ក្នុងចំណោមផលប៉ះពាល់ដូចខាងលើ សូមរៀបចំពាក្យបណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ (ឬដោយផ្ទាល់មាត់) ផ្ញើមកកាន់គណៈកម្មការទទួលដោះស្រាយបណ្តឹងតវ៉ាថ្នាក់ខេត្ត នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរដ្ឋបាលឃុំ រដ្ឋបាលស្រុក ឬតំណាងសហគមន៍របស់លោកអ្នក។

## ការឆ្លើយតបទៅនឹងបណ្តឹងតវ៉ា

១. គណៈកម្មការទទួលដោះស្រាយបណ្តឹងតវ៉ា នឹងជូនដំណឹងទៅអ្នកដាក់ពាក្យបណ្តឹងតវ៉ាវិញក្នុងរយៈពេល ៥ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្តឹងតវ៉ា។

២. ការពិនិត្យដោះស្រាយបណ្តឹងតវ៉ា នឹងត្រូវចំណាយពេល ៣០ថ្ងៃនៃថ្ងៃធ្វើការ (ដោយបូកបញ្ចូលទាំងរយៈពេលស៊ើបអង្កេតប្រមូលភស្តុតាងក្នុងករណីចាំបាច់) បន្ទាប់ពីបណ្តឹងតវ៉ា ត្រូវបានដាក់ជូនគណៈកម្មការដោះស្រាយបណ្តឹងតវ៉ា។

## វិធីដាក់ពាក្យបណ្តឹងតវ៉ា?

បុគ្គលគ្រប់រូបដែលទទួលរងផលប៉ះពាល់អវិជ្ជមានដោយសារគម្រោងឡាសិត៣ អាចមកទាក់ទងស្នើសុំទម្រង់ពាក្យបណ្តឹងពីគណៈកម្មការទទួលដោះស្រាយបណ្តឹងតវ៉ាថ្នាក់ខេត្ត នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ដែលខ្លួនរស់នៅ។ ដើមបណ្តឹង អាចដាក់ពាក្យបណ្តឹងតវ៉ារបស់ខ្លួនដោយផ្ទាល់តាមវិធីណាមួយក្នុងចំណោមវិធីទាំងបីដូចខាងក្រោម÷

១. ដាក់ពាក្យបណ្តឹងតវ៉ាចូលក្នុងប្រអប់ទទួលបណ្តឹងតវ៉ារបស់គម្រោងឡាសិត ៣ ដែលមាននៅសហគមន៍ រដ្ឋបាលឃុំ រដ្ឋបាលស្រុក និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ឬ

២. ផ្ញើតាមរយៈសារអេឡិចត្រូនិក (អ៊ីម៉េល): LASEDIIIGRM@GMAIL.COM

៣. ឬដាក់ពាក្យបណ្តឹងតវ៉ាតាមប្រព័ន្ធអនឡាញ តាមអាសយដ្ឋាន÷ www.lased.mlmupc.gov.kh

